# ការបង្កើនប្រសិទ្ធភាពនៃវិធីសាស្រ្តបង្រៀន

នៅក្នុងវគ្គសិក្សា "ការបង្កើនប្រសិទ្ធភាពនៃវិធីសាស្រ្តបង្រៀន" ដែលមានការអនុវត្តជាក់ស្តែងនេះ អ្នកសិក្សានឹងបានអនុវត្តវិធីសាស្រ្តបង្រៀនច្បាស់ៗទាក់ទងនឹងវិធីសួរសំណួរ ការបង្កើតនិងគ្រប់គ្រងសិស្សជាក្រុម ការវាយតម្លៃសម្រាប់ការកែលម្អ ការស្វែងយល់ពីដំណើរការលូតលាស់ផ្នែកខួរក្បាល និងការចងចាំរយៈពេលខ្លីនិងវែងរបស់កុមារ និងបច្ចេកទេសផ្សេងៗជាច្រើនទៀត។ ក្នុងអំឡុងពេលសិក្សានិងអនុវត្តក្នុងវគ្គសិក្សានេះ អ្នកសិក្សានឹងទទួលបានមតិកែលម្អជាប្រចាំដែលនឹងជួយឱ្យបានសម្រេចគោលដៅកែលម្អដែលខ្លួនបានកំណត់ និងជម្រុញលទ្ធផលសិក្សារបស់សិស្សឱ្យប្រសើរឡើង។ ដើម្បីបង្កភាពងាយស្រួលដល់អ្នកសិក្សា កិច្ចការដែលត្រូវធ្វើសម្រាប់ឆ្លុះបញ្ចាំងអំពីការយល់ដឹងក្នុងវគ្គសិក្សានេះ អ្នកសិក្សាត្រូវប្រើប្រាស់បច្ចេកទេសបង្រៀនទាំងនេះនៅក្នុងថ្នាក់ដែលខ្លួនបង្រៀនផ្ទាល់។

## លទ្ធផលសិក្សារំពឹងទុក

អ្នកសិក្សានឹង៖

- បានអនុវត្តបច្ចេកទេសងាយៗប៉ុន្តែមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្រៀន
- បានសហការយ៉ាងជិតស្និទ្ធជាមួយមិត្តរួមការងារដើម្បីកំណត់ចំណុចដែលត្រូវកែលម្អ និងរួមគ្នាដើម្បីអភិវឌ្ឍឱ្យប្រសើរឡើង។
- បានបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមសាលារៀនរបស់ខ្លួនដើម្បីបន្តនិរន្តរភាពនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។